## សៀវភៅណែនាំ
Field Guide

# ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ
# System of Rice Intensification



២០១៣

# សៀវភៅណែនាំ
Field Guide

# ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ
System of Rice Intensification

ឯកឧត្តមបណ្ឌិត ចន្ទ សារុន
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២០១២

# អារម្ភកថា

មើលឃើញវាលស្រែស្គួតក្រៀមនារដូវប្រាំង ដោយខ្វះទឹកស្រោចស្រព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានកំណត់យ៉ាងច្បាស់ថា នេះគឺជាសក្តានុពល ដ៏ធំធេងដែលកម្ពុជា មិនទាន់បានប្រើប្រាស់ ។

នៅក្រោមក្រសែភ្នែកដ៏មុតស្រួចរបស់រដ្ឋបុរស សក្តានុពលដែលនៅលាក់កប់ពីក្រោមបញ្ហាប្រឈមដ៏ស្រួចស្រាវ ត្រូវបានគាស់រម្លេច ហើយប្រែក្លាយទៅជាកាលានុវត្តភាពដ៏កម្រ និងដ៏សម្បើមសម្រាប់ការអភិវឌ្ឍ ។

ផ្តើមចេញពីនេះ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសប្រកបដោយមហិច្ឆិតា អំពីចក្ខុវិស័យរបស់សម្តេច ដែលចង់ឲ្យកម្ពុជាក្លាយជាប្រទេសនាំចេញ"**អង្ករ-មាសស**" យ៉ាងសំខាន់នៅលើទីផ្សារអន្តរជាតិនៅក្នុងអនាគតមិនយូរប៉ុន្មានខាងមុខ ។

ក្នុងន័យនេះរាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ ២០១៥ ជាឆ្នាំគោលដើម្បី : (១) ជំរុញការផលិតស្រូវលើសឲ្យបានច្រើនជាង ៤លានតោន ក្នុងនោះបរិមាណអង្ករសម្រាប់នាំចេញ ត្រូវសម្រេចឲ្យបានយ៉ាងតិច ១លានតោន និង (២) ធ្វើឲ្យអង្ករ កម្ពុជា ត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ។

ស្របតាមចក្ខុវិស័យខាងលើរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានតួនាទីដ៏សំខាន់ដើម្បីធានាឲ្យបាននូវសុវត្ថិភាពស្បៀង សំរាប់ប្រជាពលរដ្ឋគ្រប់រូប ធ្វើឲ្យកំណើននៃផលិតកម្មកសិកម្មមាននិរន្តភាព ជំរុញការកែច្នៃ និងរកទីផ្សារសំរាប់ផលិតផលកសិកម្ម ។ ដើម្បីចូលរួមសម្រេចនូវគោលដៅនេះ ខ្ញុំបាទបានចងក្រងនូវ

សៀវភៅណែនាំស្តីពី **"ប្រព័ន្ធប្រពល វប្បកម្មដំណាំស្រូវ"** នេះសម្រាប់ជាត្រីវិស័យក្នុងការអប់រំ បណ្តុះបណ្តាលដល់អ្នកផ្សព្វផ្សាយ និងកសិករក្នុងគោលបំណងលើកស្ទួយកំរិតយល់ដឹងរបស់គាត់អំពីបច្ចេកទេសសមស្រប និងការថែរក្សានូវប្រព័ន្ធនៃការដាំដុះដំណាំស្រូវ ដែលប្រើប្រាស់ទុនផលិតទាបតែធានាបាននូវទិន្នផលខ្ពស់ និងគុណភាពបរិស្ថានល្អប្រសើរ។

សៀវភៅណែនាំនេះ បានរៀបចំ និងចងក្រងឡើងតាមរយៈការស្រាវជ្រាវបណ្ណាល័យសាស្ត្រ និងប្រមូលបទពិសោធន៍របស់កសិករនៅ ស្រុកត្រាំកក់ ខេត្តតាកែវ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំនេះនឹងផ្តល់នូវគំនិតថ្មីជាច្រើនដល់កសិករ ក្នុងការកែលំអផលិតកម្មដំណាំស្រូវ ដែលយើងទាំងអស់គ្នាតែងគិតថា **ស្រូវ គឺជាធនាគារ** របស់កសិករ ។

សូមអរគុណ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១២



# មាតិកាអត្ថបទ


| ចំណងជើងអត្ថបទ | ទំព័រ |
|---|---|
| សៀវភៅណែនាំ | ១ |
| អារម្ភកថា | ៣ |
| មាតិកាអត្ថបទ | ៥ |
| ១- ប្រវត្តិរបស់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ | ៧ |
| ២- ដំណាក់កាលលូតលាស់របស់ដំណាំស្រូវ | ៨ |
| ក- វគ្គលូតលាស់ | ៨ |
| ខ- វគ្គបង្កើតផល | ៩ |
| គ- វគ្គទុំ | ១០ |
| ៣- គោលការណ៍ និងបច្ចេកទេសរបស់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ | ១១ |
| ក- គោលការណ៍របស់ ប.វ.ស | ១១ |
| ខ- បច្ចេកទេសនៃប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ | ១២ |
| គ- ភាពខុសគ្នារវាងផលិតកម្មដំណាំស្រូវតាមទំលាប់ និងតាម ប.វ.ស | ១៤ |

១៥០.០០០ គ្រួសារ លើភូមិចំនួនប្រមាណ ៥,១៨១ភូមិ នៅក្នុង ២៤រាជធានី ខេត្ត ដោយទទួលទិន្នផលជាមធ្យមចំនួន ៣.៩០តោន ក្នុង១ហិកតា ខណៈដែលទិន្នផលជាមធ្យមស្រូវវស្សាឆ្នាំ ២០១១ ទទួលបានតែ ២.៩២តោន ក្នុង១ហិកតាប៉ុណ្ណោះ ។

## ២- ដំណាក់កាលលូតលាស់របស់ដំណាំស្រូវ

ការយល់ដឹងពីដំណាក់កាលលូតលាស់របស់ដំណាំស្រូវមានសារៈសំខាន់ណាស់ ព្រោះធ្វើឲ្យកសិករអាចគ្រប់គ្រងដំណាំស្រូវរបស់គាត់បានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស និងអាចជៀសវាងបាននូវការបាត់បង់ទិន្នផលដោយសារកត្តាចង្រៃផ្សេងៗទៀត។

ការលូតលាស់ដំណាំស្រូវ ត្រូវបានចែកចេញជា៣វគ្គសំខាន់ៗគឺៈ

### ក- វគ្គលូតលាស់

រយៈពេលនៃវគ្គលូតលាស់របស់ដំណាំស្រូវ អាស្រ័យទៅនឹងប្រភេទស្រូវ (ប្រកាន់រដូវ ឬ មិនប្រកាន់រដូវ) និងអាយុកាលនៃពូជនិមួយៗ។

វគ្គលូតលាស់របស់ដំណាំស្រូវចែកចេញជា៤ដំណាក់កាលគឺៈ

- ដំណាក់កាលដុះពន្លក (ចាប់ផ្តើមពីគ្រាប់ស្រូវ ដល់ស្រូវដុះពន្លកស្លឹកទីមួយ)
- ដំណាក់កាលសំណាប (ចាប់ពីស្រូវដុះស្លឹកទីមួយ ដល់ស្រូវចាប់ផ្តើមបែកគុម្ព)



- ដំណាក់កាលបែកគុម្ព (ចាប់ពីស្រូវបែកគុម្ពដំបូង ដល់ស្រូវបែកគុម្ពពេញទំហឹង) និង
- ដំណាក់កាលពន្លូតដើម (ចាប់ពីស្រូវបែកគុម្ពពេញទំហឹងដល់ស្រូវចាប់ ផ្តើមពន្លកកកួរ)។




នៅក្នុងវគ្គលូតលាស់នេះ អ្នកត្រូវគិតពីការរៀបចំពូជ ការពិនិត្យ គុណភាពគ្រាប់ពូជ ការត្រាំនិងបណ្តុះគ្រាប់ពូជ ការជ្រើសរើសនិង រៀបចំទីកន្លែងសំរាប់សាប ការថែទាំសំណាប ការរៀបចំដីសំរាប់ស្ទូង ការដាក់ជី និងការថែទាំសន្ទូង។

### ខ- វគ្គបង្កើតផលៈ

វគ្គបង្កើតផលមានរយៈពេល ៣៥ថ្ងៃ ដោយគិតពីស្រូវចាប់ផ្តើមពន្លកកកួររហូតដល់ចេញផ្កា ។ ក្នុងវគ្គបង្កើតផលនេះចាំបាច់ត្រូវថែទាំទឹកឲ្យបានល្អ បាចជីបំប៉ន និងកំចាត់សត្វល្អិតចង្រៃនិងកណ្តុរ។

វគ្គបង្កើតផលចែកជា ៣ ដំណាក់កាលគឺ:
- ដំណាក់កាលពន្លកកក្ងរ (ចាប់ផ្ដើមពីស្រូវពន្លកកក្ងរដល់ស្រូវផើម)
- ដំណាក់កាលចេញក្ងរ (ចាប់ពីស្រូវផើមដល់ស្រូវចេញក្ងរផុតពីស្លឹកទង់ជ័យ) និង
- ដំណាក់កាលចេញផ្កា (ចាប់ពីស្រូវចេញក្ងរផុតដល់ស្រូវរោយលំអង)។




**គ- វគ្គទុំ:**

វគ្គទុំមានរយៈពេល ៣០ថ្ងៃ ដោយគិតចាប់ពីស្រូវដាក់ទឹកដោះ រហូតដល់ពេលស្រូវទុំពេញលេញ ។

វគ្គទុំចែកចេញជា ៣ដំណាក់កាលគឺ:
- ដំណាក់កាលដាក់ទឹកដោះ
- ដំណាក់កាលដាក់ម្សៅ និង
- ដំណាក់កាលទុំពេញលេញ។



នៅក្នុងវគ្គទុំនេះ អ្នកត្រូវប្រុងប្រយ័ត្នលើបញ្ហាមួយចំនួនដូចជាការបំផ្លាញរបស់ ស្រឹង កណ្ដុរ ចាប និងពេលវេលានៃការប្រមូលផល។

## ៣-គោលការណ៍ និងបច្ចេកទេសរបស់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ

**ក- គោលការណ៍របស់ ប.រ.ស:**

- ដំណាំស្រូវមិនមែនជារុក្ខជាតិទឹក ប៉ុន្តែវាធន់ទ្រាំទៅនឹងទឹក ។ ប្រសិនបើដំណាំស្រូវដុះក្នុងទឹកតិចៗនោះ សក្ដានុពលនៃការលូតលាស់និងការបែកគុម្ពរបស់វាបានល្អ
- ដំណាំស្រូវ នឹងកាត់បន្ថយសក្ដានុពលធម្មជាតិក្នុងការបែកគុម្ព ប្រសិនបើអ្នកស្ទូងសំណាប មានអាយុលើសពី ១៥ថ្ងៃឡើងទៅ
- ដំណាំស្រូវនឹងមានសក្ដានុពលបែកគុម្ពខ្ពស់ ប្រសិនបើអ្នកកាត់បន្ថយនូវភាពរន្ធត់របស់វា(ឧទាហរណ៍: ការដកសំណាបពីថ្នាល រួចយកមកបោកនឹងប្រអប់ជើងអ្នកខ្លាំងៗ បន្ទាប់មកយកវាមកចងរឹតជាកណ្ដាប់ជាដើម ។ល។)
- ប្រសិនបើដំណាំស្រូវដុះតែឯងនោះ វានឹងលូតលាស់ហើយបែកគុម្ពតាមសក្ដានុពលធម្មជាតិរបស់វា
- ដំណាំស្រូវនឹងលូតលាស់បានល្អ ប្រសិនបើដីធូរមានខ្យល់ចេញ ចូល និងមានជីជាតិគ្រប់គ្រាន់។

## ខ- បច្ចេកទេសនៃប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវៈ

បច្ចេកទេសសំខាន់ៗចំនួន១២ នៃប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ដើម្បីឲ្យស្រូវផ្តល់ទិន្នផលខ្ពស់គឺៈ

- ប្រើជីធម្មជាតិ ជាពិសេសជីកំប៉ុស្ត ដើម្បីឲ្យដីផុសល្អ
- ប្រើពូជសុទ្ធល្អ និងរើសតែគ្រាប់ពេញល្អសំរាប់យកទៅសាប
- ធ្វើថ្នាលសំណាបគោក ហើយសាបស្តើង ដើម្បីឲ្យសំណាបថ្លោសល្អ
- ដកថ្នមៗ យកតែសំណាបណាថ្លោសៗ រួចយកទៅស្ទូងភ្លាមៗ
- ស្ទូងសំណាបអាយុខ្ចី យកល្អអាយុត្រូវតិចជាង ១៥ថ្ងៃ
- ស្ទូងចាប់ស្តើង យកល្អស្ទូងតែ១ដើមក្នុង១គុម្ព
- ស្ទូងថ្នមៗ រាក់ៗ និងកុំបត់ឫសដូចផ្លែសន្ទូច
- ស្ទូងជាជួរដោយចំងាយពីគុម្ពមួយទៅគុម្ពមួយស្មើៗគ្នា
- ស្ទូងឲ្យរង្វើលពីគ្នា ដោយទុកចន្លោះពី ២-៤តឹក
- ជៀសវាងមានទឹកដក់ច្រើននៅក្នុងស្រែ ពេលស្រូវកំពុងលូតលាស់
- ដកស្មៅនិងបំផុសដីឲ្យបាន២-៤ដង ដើម្បីឲ្យខ្យល់ចេញចូលល្អ និង
- ធ្វើដីឲ្យបានរាបស្មើ និងមានប្រព័ន្ធសម្រាប់បញ្ចេញទឹក។





### គ- ភាពខុសគ្នារវាងផលិតកម្មដំណាំស្រូវតាមទំលាប់ និងតាម ប.វ.ស:

| តាមទំលាប់ | តាម ប.វ.ស |
|---|---|
| - មិនបានជ្រើសរើសពូជសុទ្ធល្អ និងគ្រាប់ពេញទៅសាប<br>- រក្សាទឹកទុកច្រើននៅក្នុងថ្នាលសំណាប និងសាបក្រាស់ ដែលនាំឲ្យសំណាបមានដើមតូច ឬរាវ<br>- ស្ទូងចាប់ធំ ដោយលាយឡំគ្នារវាងសំណាបដែលអន់ និងដើមល្អិត<br>- ស្ទូងសំណាបអាយុចាស់ ជាទូទៅលុះត្រាសំណាបអាយុលើសពី ១ខែ ទើបយកទៅស្ទូង<br>- ដកសំណាបបោកទៅនឹងប្រអប់ជើង ដែលបណ្ដាលឲ្យបាក់ដើម និងដាច់ឫសស្រូវ រួចយកមកចងរឹតជាកណ្ដាប់ និងផ្អាប់ទុក ១-២ យប់មុនយកទៅស្ទូង<br>- ស្ទូងញឹក និងមិនស្មើគ្នារវាងចន្លោះគុម្ពមួយទៅគុម្ពមួយ (ស្ទូងជាមុំចង្រ្កាន) | - ជ្រើសរើសពូជសុទ្ធល្អ និងគ្រាប់ពេញទៅសាប<br>- រៀបចំថ្នាលសំណាបគោកដូចរងស្លែ ហើយសាបស្តើង (ពូជ០,៥គ.ក្រលើផ្ទៃដី៥ម៉ែត្រក្រឡា) ដើម្បីឲ្យដើមសំណាបថ្លោសល្អ<br>- ដកយកតែសំណាបដែលថ្លោសៗយកទៅស្ទូងហើយស្ទូងតែ១-២ដើមប៉ុណ្ណោះក្នុង១គុម្ព<br>- ស្ទូងសំណាបខ្ចីអាយុតិចជាង ១៥ថ្ងៃ<br>- ដកថ្នមៗ មិនឲ្យបាក់ដើម និងដាច់ឫសរួចដាក់ក្នុងកាផុនឬបង្គី(មិនបោក)។ ដកភ្លាមស្ទូងភ្លាម និងស្ទូងរាក់ៗ<br>- ស្ទូងជាជួរ ចន្លោះគុម្ពពី ២០-៤០សង់ទីម៉ែត្រ ទៅតាមស្ថានភាពជីជាតិដី។ |

| តាមទំលាប់ | តាម ប.វ.ស |
|---|---|
| - រក្សាទឹកទុកក្នុងស្រែជានិច្ចក្នុងអំឡុងពេលស្ទូង និងស្រូវកំពុងលូតលាស់<br>- ដកស្មៅមិនទាន់ពេលវេលា មិនបានញឹកញាប់ និងមិនទៀងទាត់<br>- មិនប្រើប្រាស់កំទេចកំទីសំរាមជុំវិញផ្ទះ តែអាស្រ័យទាំងស្រុងទៅលើការប្រើប្រាស់ជីគីមី<br>- មិនយកចិត្តទុកដាក់បន្សុទ្ធពូជមុនពេលច្រូតកាត់សំរាប់ទុកធ្វើជាគ្រាប់ពូជ។ | - រក្សាទឹកទុកតិចៗក្នុងស្រែ យកល្អរក្សាដីស្រែគ្រាន់តែសើម ឬម្តងស្ងួតម្តងសើម<br>- ដកស្មៅបានទាន់ពេលវេលា ញឹកញាប់ និងជាទៀងទាត់<br>- ប្រើប្រាស់ជីធម្មជាតិ ជាពិសេសជីកំប៉ុស្តគោក និងជីកំប៉ុស្តទឹកបំប៉ន<br>- ធ្វើការបន្សុទ្ធពូជមុនពេលច្រូតកាត់ និងរក្សាទុកឲ្យបានត្រឹមត្រូវ។ |






## ៤- ការណែនាំបន្ថែមពីបច្ចេកទេសមួយចំនួនរបស់ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ

### ក- ការជ្រើសរើសគ្រាប់ពូជៈ

ការជ្រើសរើស និងសំរាំងគ្រាប់ពូជស្រូវដែលល្អសំរាប់ធ្វើការដាំដុះ ក្នុងស្រែរបស់អ្នកមានសារៈសំខាន់ណាស់ ព្រោះគ្រាប់ពូជល្អអាចដុះលូតលាស់បានឆាប់រហ័ស និងផ្តល់ទិន្នផលខ្ពស់។ ក្នុងន័យនេះ អ្នកគប្បីពិចារណាទៅលើលក្ខណៈពិសេសមួយចំនួនរបស់ដំណាំស្រូវ ដែលអ្នកត្រូវជ្រើសរើសយកមកដាំដូចជាៈ

- ពូជផ្តល់ទិន្នផលខ្ពស់
- គ្រាប់ពូជសុទ្ធដែលមានគុណភាព (ដំណុះគ្រាប់ពី៨៥%ឡើងទៅ)
- រយៈពេលលូតលាស់(ស្រូវស្រាល ឬស្រូវកណ្តាល)
- ភាពធន់ទ្រាំនឹងការរាំងស្ងួត សត្វល្អិតចង្រៃនិងជំងឺ
- គុណភាពគ្រាប់អង្ករ និងរសជាតិ



## ខ- ការជ្រើសរើស និងការរៀបចំទីកន្លែងសំរាប់សាបៈ

ត្រូវជ្រើសរើសទីកន្លែង សំរាប់ធ្វើថ្នាលសំណាបឲ្យបានល្អប្រសើរបំផុត ។ កន្លែងដែលជ្រើសរើសនោះត្រូវៈ

- ងាយស្រួលក្នុងការបញ្ចេញទឹក
- ងាយស្រួលការពារសត្វពាហនៈ និងបក្សី
- ដីថ្នាលត្រូវមានជីជាតិល្អ
- ស្ថិតនៅឆ្ងាយពីម្លប់រុក្ខជាតិ។

ដើម្បីស្ទូងនៅលើផ្ទៃដី១ហិកតា អ្នកត្រូវមានផ្ទៃដីសំរាប់ធ្វើជាថ្នាលសំណាបពី១៥០-២០០ម៉ែត្រក្រឡា។ អ្នកត្រូវដាក់ជីធម្មជាតិ បន្ទាប់មកត្រូវរាស់ឲ្យបានហ្មត់ចត់ល្អ ហើយលើករងជាថ្នាលតូចៗដូច រងស្ពៃដែលមានទទឹងពី ១,៥-២ ម៉ែត្រ ឯបណ្ដោយអាស្រ័យទៅតាម ទំហំដីស្រែរបស់អ្នក។ ការធ្វើថ្នាលសំណាបជារងធ្វើឲ្យងាយស្រួល ក្នុងការសាប ការស្រោចទឹក ឬបញ្ចេញទឹក ការបោចស្មៅនិង ការកំចាត់សត្វល្អិតចង្រៃ។

## គ- ការប្រើប្រាស់ជីលើថ្នាលសំណាបៈ

អ្នកគប្បីភ្ជួរដីឲ្យសព្វល្អក្នុងជម្រៅប្រមាណ១៥សង់ទីម៉ែត្រ (ជិតមួយចំអាម) និងហាលឲ្យបានពី ៧-១០ថ្ងៃ មុនពេលរៀបចំវាធ្វើជាថ្នាលសំណាប។ ត្រូវប្រើជីលាមកសត្វ ឬជីកំប៉ុស្តដែលរលួយល្អ សំរាប់ទ្រាប់បាតថ្នាលសំណាប។ អ្នកអាចប្រើប្រាស់ជីលាមកសត្វ ឬជីកំប៉ុស្តចំនួន១-២រទេះគោ សំរាប់ផ្ទៃដី១០០ម៉ែត្រក្រឡា រួចរាស់លប់បំបែកឲ្យសព្វ និងកៀរវាឲ្យស្មើល្អ។



## ឃ- ការសំអាតគ្រាប់ពូជ

សំអាតគ្រាប់ពូជឲ្យបានស្អាតល្អមុនពេលយកទៅត្រាំនិងបណ្ដុះជាការចាំបាច់ណាស់ ពីព្រោះគ្រាប់ពូជដែលអ្នកមិនបានសំអាតវា អាចមានលាយសំដី ឬគ្រាប់មិនពេញទឹក (ស្កៀត) ដែលជាហេតុនាំឲ្យសំណាបដុះមិនល្អ។ ដូចនេះអ្នកគប្បីធ្វើការសំអាត និងយកតែគ្រាប់ដែលពេញល្អយកទៅសាប។ គ្រាប់ពេញល្អធ្វើឲ្យសំណាបដុះថ្លោសល្អ និងមានកំលាំងខ្លាំង ពេលអ្នកដកវាយកទៅស្ទូង សន្ទូងនោះនឹងឆាប់លូតលាស់។

ដើម្បីញែកគ្រាប់ពេញ និងគ្រាប់តូចស្កៀត ឬសំដីស្រូវចេញពីគ្នាអ្នកត្រូវអនុវត្តតាមលំដាប់លំដោយដូចតទៅៈ

- ដាក់ពងមាន់ ឬពងទាចូលក្នុងធុងទឹក រួចចាក់អំបិលមួយចំនួនចូលទៅក្នុងធុងទឹកនោះ បន្ទាប់មកកូរវាឲ្យរលាយអស់ ។ ប្រសិនបើស៊ុតពុំទាន់អណ្ដែតឡើងលើផ្ទៃទឹកទេអ្នកត្រូវចាក់អំបិលបន្ថែម រហូតដល់ស៊ុតនោះអណ្ដែតឡើងលើផ្ទៃទឹក
- ចាក់គ្រាប់ពូជដែលត្រូវសាបឲ្យបានពាក់កណ្ដាលធុងរួចកូរឲ្យសព្វ
- កៀរយកចេញនូវសំដី និងគ្រាប់ស្រូវណាដែលអណ្ដែតប៉ែលប៉ោល
- ស្រង់យកគ្រាប់ដែលលិចក្នុងទឹកទុកមួយកន្លែង ហើយធ្វើដូចនេះសារឡើងវិញរហូតដល់អស់គ្រាប់ពូជដែលត្រូវយកទៅសាប
- គ្រាប់ពូជស្រូវល្អដែលបានស្រង់ទុកនោះត្រូវយកទៅលាងជាមួយទឹក ដើម្បីឲ្យអស់ជាតិអំបិលសិនមុននឹងយកទៅត្រាំបើពុំដូច្នោះទេនោះគ្រាប់ពូជពុំអាចដុះបានឡើយ។




## ង- ការត្រាំ និងផ្អាប់គ្រាប់ពូជ:

ការត្រាំ និងផ្អាប់គ្រាប់ពូជ គឺជាដំណើរការចំនួនពីរក្នុងការបណ្ដុះគ្រាប់ពូជ។ គ្រាប់ពូជដែលបណ្ដុះរួចយកទៅសាបក្នុងថ្នាលពុំសូវមានការបំផ្លាញពីសត្វល្អិត សត្វស្លាប ជំងឺ ស្មៅ ឬសត្វចង្រៃផ្សេងៗទេ ពីព្រោះវាដុះលូតលាស់ឆាប់រហ័ស។ អ្នកត្រូវគិតគូរឲ្យបានច្បាស់អំពីបរិមាណ និងគុណភាពគ្រាប់ពូជមុននឹងយកមកត្រាំដើម្បីសាប។ គ្រាប់ពូជដែលមានគុណភាពល្អត្រូវមានដំណុះពី ៨៥%ឡើងទៅ។ ដើម្បីយល់ដឹងពីគុណភាពគ្រាប់ យើងត្រូវយកគ្រាប់ពូជ១០០គ្រាប់មកតំរៀបលើបន្ទះក្រណាត់មួយរួចរុំវាឲ្យជាប់ បន្ទាប់មកត្រូវត្រាំក្នុងទឹករយៈពេល២៤ម៉ោង សំងិលវា ដោយរក្សាសំណើម និងកំដៅរយៈពេល៤៨ម៉ោង រួចហើយយើងលាក្រណាត់រាប់នូវគ្រាប់ដែលដុះ (ចាប់ពី១សង់ទីម៉ែត្រ ឡើងទៅ) តើមានចំនួនប៉ុន្មាន? ចំនួនដែលបានមកនេះ គឺជាភាគរយ នៃដំណុះគ្រាប់ពូជ។ សំរាប់ផ្ទៃដី១ហិកតា ត្រូវការគ្រាប់ពូជមានគុណភាពល្អពី ១០-១៥គីឡូក្រាម។ បើគុណភាពដំណុះតិចជាង ៨៥% ត្រូវបន្ថែមគ្រាប់ពូជ (ឬប្ដូរពូជផ្សេង)



ដើម្បីឲ្យមានសំណាបគ្រប់គ្រាន់សំរាប់ស្ទូង។ មុនត្រាំត្រូវលាងគ្រាប់ពូជឲ្យបានស្អាត រួចច្រកទៅក្នុងបាវដោយចងមាត់ កុំឲ្យតឹងពេកហើយត្រាំក្នុងទឹកស្អាតរយៈពេល២៤ម៉ោង។ បន្ទាប់មកត្រូវលាងគ្រាប់ដែលត្រាំរួចឲ្យស្អាតហើយយកវាទៅដាក់ក្នុងម្លប់ ដោយពង្រាបបាវស្រូវឲ្យមានកំរាស់ពី១០-១៥សង់ទីម៉ែត្រ និងយកចំបើងគ្របពីលើបាវដើម្បីបង្កើនកំដៅដែលជួយជំរុញឲ្យគ្រាប់ពូជដុះបានល្អ។ ត្រូវលើកត្រឡប់បាវគ្រាប់ពូជពីលើចុះមកក្រោម រយៈពេល១២ម៉ោង រួចស្រោចទឹកផ្សើមតិចៗ។




## ច- ការសាប:

អ្នកត្រូវសាបគ្រាប់ពូជឲ្យស្មើល្អ គឺក្នុងកម្រិត១០០ក្រាមក្នុង១ម៉ែត្រក្រឡា ដោយប៉ាន់ស្មានក្នុងកំរិត ១ទូកដៃ។ ការសាបញឹក ឬ ក្រាស់ពេកបណ្ដាលឲ្យដើមសំណាបតូចឆ្មារ ហើយទន់ខ្សោយ។ ការសាបគួរធ្វើនៅពេលល្ងាចដើម្បីជៀសវាងការស្វិតឬសដោយសារ កំដៅថ្ងៃហើយបើជឿជាក់ថា មានភ្លៀងធ្លាក់ខ្លាំងបន្ទាប់ពីសាប អ្នកគួរពន្យារពេលរហូតដល់ភ្លៀងរួច ដើម្បីកុំឲ្យគ្រាប់រមូរចូលគ្នា ឬហូរចូលក្នុងចង្អូររង។

## ឆ- ការរៀបចំដីៈ

ការរៀបចំដីមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើការដុះលូតលាស់របស់ដំណាំស្រូវ។ បើអ្នករៀបចំដីបានល្អនោះ ដំណាំស្រូវនឹងលូតលាស់បានល្អដែរ។ ត្រូវលើកភ្លឺស្រែឲ្យបានមាំល្អដើម្បីថែរក្សាទឹក និងជីជាតិមិនឲ្យហូរចេញពីស្រែរបស់អ្នក។ ត្រូវភ្ជួររាស់ដីស្រែឲ្យបានច្រើនសារ និងមានជម្រៅយ៉ាងតិច១៥សង់ទីម៉ែត្រ ហើយរាស់ពង្រាបឲ្យបានស្មើល្អដើម្បីៈ

- កប់បញ្ចូលស្មៅ និងកាកសំណល់រុក្ខជាតិផ្សេងៗ ទៅក្នុងដីឲ្យ រលួយក្លាយជាជីសំរាប់ដំណាំស្រូវ
- ឲ្យដីធូរស្រួលស្ទូង និងឲ្យប្រព័ន្ធឫសស្រូវលូតលាស់បានល្អ
- ងាយស្រួលក្នុងការគ្រប់គ្រងទឹក
- លាយច្របល់ ឬកប់បញ្ចូលជីធម្មជាតិទៅក្នុងដី ដើម្បីបន្ថយការ ភាយធាតុចិញ្ចឹម (អាស៊ូត) ទៅក្នុងខ្យល់ និង
- បង្កើនរន្ធខ្យល់ក្នុងដី





ចំពោះដីស្រែប្រាំងឬស្រែប្រដេញទឹក អ្នកត្រូវភ្ជួរដាស់ដីចោលមុនពេលទឹកលិចព្រោះវាជួយកំចាត់ស្មៅ បង្កើនជីជាតិដី និងងាយស្រួលរៀបចំដីក្រោយពេលទឹកស្រក ដោយគ្រាន់តែរាស់ពង្រាបឲ្យស្មើល្អជាការស្រេច។

## ជ- ការប្រើប្រាស់ជីៈ

អ្នកគប្បីយកចិត្តទុកដាក់ លើការប្រើប្រាស់ជីធម្មជាតិឲ្យបានច្រើនបំផុត ព្រោះជីធម្មជាតិមានគុណសម្បត្តិច្រើនដូចជាៈ

- ធ្វើឲ្យដីផុសល្អ
- អាចរក្សាសំណើមក្នុងដីបានយូរ
- ជួយបង្កើនជីជាតិដី
- ជួយបង្កើនវត្តមាននិងសកម្មភាពអតិសុខុមប្រាណ (មីក្រូសរីរាង្គ) មានប្រយោជន៍នៅក្នុងដី
- បន្ថយការចំណាយក្នុងការទិញជីគីមី និង
- ជួយរក្សាបរិស្ថានបានល្អ។



ជីធម្មជាតិដែលត្រូវប្រើប្រាស់នោះមានៈ ជីលាមកសត្វ ជីកំប៉ុស្ត និងជីស្រស់ (ពួកអំបូរសណ្តែក ស្នោ ចកអាសូឡា ...)។ ម្យ៉ាងទៀត ចំបើងនិងជញ្ជ្រាំងស្រូវក៏ផ្តល់ជីជាតិសំខាន់សំរាប់ដីស្រែដែរ ដូចនេះគប្បីភ្ជួរលប់ឲ្យបានល្អ ដោយមិនត្រូវដុតវាចោលឡើយ។ គប្បីប្រើប្រាស់ជីលាមកសត្វ និង ជីកំប៉ុស្ត ដែលរលួយល្អទ្រាប់បាត ក្នុងកម្រិតពី១០-២០តោន ក្នុង១ហិកតា ហើយភ្ជួរលប់នៅពេលភ្ជួរចុងក្រោយបង្អស់។ ចំពោះជីស្រស់ និងកាកសំណល់រុក្ខជាតិផ្សេងៗ ត្រូវភ្ជួរលប់មុនថ្ងៃស្ទូងពី១០-១៥ថ្ងៃ ដើម្បីឲ្យរុក្ខជាតិទាំងនោះ រលួយបានល្អ។

**ឈ- ការគ្រប់គ្រងទឹកៈ**

ការគ្រប់គ្រងទឹកបានត្រឹមត្រូវល្អ ធ្វើឲ្យដំណាំស្រូវដុះលូតលាស់បានល្អ ហើយអាចកាត់បន្ថយនូវការខូចខាតទិន្នផលដែលបណ្តាលមកពីការរាំងស្ងួត។ ដូចនេះសំរាប់កន្លែងដែលមានភ្លៀងពុំសូវទៀងទាត់ ហើយឆាប់រីងស្ងួត អ្នកគប្បីគិតគូរលើកត្តាសំខាន់ៗខ្លះដូចជាៈ

- ថែទាំភ្លឺស្រែឲ្យបានល្អ តែកុំរក្សាទុកទឹកច្រើនពេក នៅពេលដំណាំស្រូវកំពុងស្ថិតនៅក្នុងវគ្គលូតលាស់ ជាពិសេសដំណាក់កាលបែកគុម្ព
- កំចាត់ស្មៅចង្រៃឲ្យអស់ពីស្រែ ព្រោះស្មៅភាគច្រើន ស្រូបយកទឹក និងជីជាតិពីដីស្រែខ្លាំងជាងដំណាំស្រូវ
- ប្រសិនបើធ្វើទៅបាន គួរជីកស្រះក្នុងស្រែទំហំ ២០ម៉ែត្រx១០ម៉ែត្រ ដើម្បីផ្ទុកទឹកសម្រាប់ស្រោចស្រពពេលជួបប្រទះនូវការ រាំងស្ងួត និងអាចប្រើសំរាប់ចិញ្ចឹមត្រីផង។



ក្រោយពេលស្ទូងរួច អ្នកត្រូវថែរក្សាទឹកក្នុងស្រែឲ្យមានជម្រៅមិនលើសពី២-៣សង់ទីម៉ែត្រ ឬម្តងស្ងួតម្តងសើម ឬគ្រាន់តែសើមតិចៗបានហើយ។ ការថែរក្សាទឹកក្នុងស្រែនេះធ្វើឡើងដើម្បីៈ

* បង្ក្រាបការលូតលាស់របស់ស្មៅ
* ជួយដល់ដំណាំស្រូវក្នុងការស្រូបយកជីជាតិពីដី
* ជួយរំលាយសារធាតុសរីរាង្គ
* ធ្វើឲ្យដំណាំស្រូវអាចបែកគុម្ពបានច្រើន។

ចំណាំៈ សំណាបដែលស្ទូងរួចអាចងាប់កាលណាស្រែអ្នកស្ងួតហែងឬមានទឹកច្រើនពេក។ គួររក្សាទឹកក្នុងស្រែឲ្យបានគ្រប់គ្រាន់ក្នុងពេលដែលស្រូវស្ថិតក្នុងវគ្គបង្កើតផល (ផើម-ដាក់ទឹកដោះ) ព្រោះភាពស្ងួតហែងក្នុងវគ្គនេះធ្វើឲ្យស្រូវស្កក ឬដាក់គ្រាប់មិនពេញ។

**ញ- ការកំចាត់ស្មៅ និងការបាចជីបំប៉នៈ**

ត្រូវដកស្មៅចង្រៃ ដែលដុះលាយជាមួយដំណាំស្រូវឲ្យបានស្អាត ព្រោះស្មៅអាចប្រជែងដណ្តើមយកសារធាតុចិញ្ចឹម សំណើម និងពន្លឺពីដំណាំស្រូវរបស់អ្នក លើសពីនេះទៀតវាជាជំរកសំរាប់សត្វល្អិតចង្រៃ និងកណ្តុរ។ អ្នកអាចបាចជីបំប៉នបន្ថែមទៀត ជាពិសេសជីកំប៉ុស្តដែលរលួយល្អ នៅពេលស្រូវបែកគុម្ព ដើម្បីបង្កើនការបែកគុម្ពរបស់វាឲ្យបានជាអតិបរមា និងបាចម្តងទៀតនៅពេលស្រូវចាប់ផ្តើមពន្លកកក្ខួរ ដើម្បីឲ្យ ស្រូវមានក្ខួរធំហើយវែងល្អ។



## ៥-ការប្រមូលទុកដាក់ផលស្រូវ

### ក- ការប្រមូលផល:

បញ្ហាសំខាន់នៃការប្រមូលផល គឺការច្រូតកាត់ឲ្យបានទាន់ពេលវេលា ដើម្បីជៀសវាងនូវការបាត់បង់ទិន្នផល។ មុនធ្វើការច្រូតកាត់សំខាន់បំផុត គឺត្រូវវិនិច្ឆ័យលើភាពទុំរបស់ស្រូវឲ្យបានត្រឹមត្រូវ។ ពេលវេលាសមស្របសំរាប់ការច្រូតកាត់ គឺនៅពេលដែលគ្រាប់ស្រូវ ៨០-៨៥% នៅចុងកួរមានពណ៌ លឿងដូចចំបើងហើយគ្រាប់នៅគល់កួរស្ថិតក្នុងដំណាក់កាលម្សៅខ្លាំង។ ការច្រូតកាត់បានទាន់ពេលវេលានេះអាចធ្វើឲ្យ :



- គុណភាពអង្ករល្អ មានតំលៃខ្ពស់នៅទីផ្សារ
- មិនសូវបាត់បង់ទិន្នផល ដែលបណ្តាលមកពីការដួលដើម បាក់កួរ ជ្រុះគ្រាប់ ឬការបំផ្លាញរបស់ចាប និងកណ្តុរ។



### ខ- ការទុកដាក់ផលស្រូវ:

គ្រាប់ស្រូវដែលទើបច្រូតកាត់បោកបែនរួចវាអាចមានសំណើមគ្រាប់ពី ១៨-២៥% ។ អ្នកមិនអាចយកគ្រាប់ស្រូវដែលមានសំណើមខ្ពស់បែបនេះទៅស្តុកបានទេ ព្រោះគ្រាប់ស្រូវនោះ នឹងត្រូវពុកផុយដោយសារពួកផ្សិត និងមានសត្វល្អិតចង្រៃបំផ្លាញច្រើន។ ដូចនេះមុនពេលស្តុកត្រូវហាលគ្រាប់ស្រូវក្រោមកំដៅថ្ងៃរយៈពេល២-៣ថ្ងៃ ឲ្យបានស្ងួតល្អសិន ។ គ្រាប់ស្រូវដែលអាចស្តុកទុកបាន ត្រូវមានសំណើមប្រមាណ១៤%។ អ្នកអាចដឹងពីភាពស្ងួតរបស់គ្រាប់ស្រូវ

បានដោយខាំគ្រាប់ជាពីរកំណាត់ ហើយពិនិត្យមើល បើផ្ទៃក ខាងក្នុងគ្រាប់មានពណ៌សថ្លានោះ គ្រាប់ស្រូវស្ងួតល្មម តែបើ វាមិនមានពណ៌សថ្លាទេនោះ គ្រាប់ស្រូវមិនទាន់ស្ងួតនៅ ឡើយទេ។

ចូរកុំហាលគ្រាប់ស្រូវឲ្យស្ងួតពេក ព្រោះវានឹងបណ្តាល ឲ្យប្រេះគ្រាប់ និងបាក់គ្រាប់ច្រើននៅពេលអ្នកកិនវា។ ជង្រុក សំរាប់ដាក់ស្រូវត្រូវស្ថិតនៅកន្លែងដែលស្ងួត មានខ្យល់ចេញ ចូលល្អ និងគ្មានកណ្តុរបំផ្លាញ។ បើមានពូជស្រូវផ្សេងៗពីគ្នា ច្រើននោះអ្នកត្រូវដាក់វាដោយឡែកពីគ្នា ហើយដាក់ផ្លាក ឈ្មោះពូជឲ្យបានច្បាស់លាស់ ធ្វើដូចនេះដើម្បីកុំឲ្យពូជរបស់ អ្នកលាយចូលគ្នា។





## ៦- ការកត់ត្រាការចំណាយ និងចំណូលនៃការដាំដុះស្រូវ

ការកត់ត្រាបានច្បាស់លាស់លើការចំណាយ និង ចំណូលពីការដាំស្រូវឬផលិតកម្មអ្វីផ្សេងទៀត មានសារៈ សំខាន់ណាស់សំរាប់កសិករគ្រប់រូប ព្រោះធ្វើឲ្យគាត់យល់ ដឹងច្បាស់ពីការចំណេញ ឬខាតក្នុងការធ្វើផលិតកម្ម និង ចេះជ្រើសរើសនូវវិធីសាស្ត្រល្អៗ សំរាប់យកមកអនុវត្តក្នុង ផលិតកម្មរបស់គាត់ ដើម្បីទទួលប្រាក់ចំណេញច្រើន។

## ៧- ចំណេះដឹងទូទៅអំពីស្ថានភាពស្បៀងប្រចាំឆ្នាំ

ប្រសិនបើអ្នកចង់ដឹងជាមុន អំពីស្ថានភាពតុល្យភាព ស្បៀងប្រចាំឆ្នាំនៅក្នុងស្រុកឬសហគមន៍របស់អ្នកនោះ អ្នក គប្បីយល់ដឹងពីមេគុណ (Coefficient) និងរបៀបគណនា តាមលំដាប់លំដោយដូចខាងក្រោម:

- អ្នកត្រូវកាត់ ១៣% (៤% សំរាប់ទុកពូជ ២% សំរាប់ចំណីសត្វ និង ៧% សំរាប់ការបាត់បង់ក្រោយ ពេល ប្រមូលផល) ចេញពីបរិមាណផលស្រូវសរុប ដែលមាននៅក្នុងស្រុក ឬសហគមន៍របស់អ្នក ។
- ស្បៀងដែលមានសរុបគិតជាអង្ករដែលមាននៅក្នុង ស្រុក ឬ សហគមន៍របស់អ្នកនោះ គឺស្មើនឹងបរិមាណ ផលស្រូវសរុប ដែលនៅសល់ពីការកាត់ចេញ១៣% ខាងលើយកមកគុណ នឹង ៦៤%
- តម្រូវការស្បៀងគិតជាអង្ករសម្រាប់មនុស្សម្នាក់ក្នុង ១ឆ្នាំ គឺ ១៤៣ គីឡូក្រាម ។

ឧទាហរណ៍:

នៅក្នុងស្រុកឬសហគមន៍ អ្នកមានពលរដ្ឋចំនួន ១០.០០០ នាក់ ហើយនៅក្នុងឆ្នាំនេះស្រុក ឬសហគមន៍ ផលិតបានបរិមាណផលស្រូវសរុបចំនួន ៥.០០០តោន ដូចនេះ អ្នកអាចគណនារកតុល្យភាពស្បៀងប្រចាំឆ្នាំ របស់ស្រុក ឬសហគមន៍តាមរបៀបដូចខាងក្រោម:

* កាត់ទុក១៣% : ៥.០០០តោន x ១៣ / ១០០ = ៦៥០តោនស្រូវ

* ស្បៀងគិតជាអង្ករ : (៥,០០០តោន-៦៥០តោន) x៦៤ / ១០០
= ២.៧៨៤តោនអង្ករ

* តំរូវការស្បៀង១ឆ្នាំ = ១៤៣គីឡូក្រាម x ១០.០០០នាក់
= ១.៤៣០.០០០គីឡូក្រាម ឬ ១.៣៥៤តោនអង្ករ

* តុល្យភាពស្បៀង + ២.៧៨៤តោន-១.៤៣០តោន = ១.៣៥៤តោន

ដូច្នេះអ្នកដឹងថានៅក្នុងស្រុកឬសហគមន៍របស់អ្នក ក្នុងឆ្នាំនេះមានស្បៀងគិតជាអង្ករ ដែលនៅសល់ក្រោយពីការដកទុក **សំរាប់ហូប សំរាប់ចិញ្ចឹមសត្វ សំរាប់ពូជ** និង **សំរាប់ការខាតបង់ផ្សេងៗ មាន** ចំនួន១.៣៥៤តោន។

ប្រសិនបើតុល្យភាពស្បៀងមាន **សញ្ញាដក** (-) នៅពីមុខតួរលេខនោះមានន័យថាស្រុក ឬសហគមន៍អ្នកមានការខ្វះខាតស្បៀង។



# ឯកសារយោង


១- ក្រសួងកសិកម្មជំរុញការប្តូរពូជ និងបច្ចេកទេសថ្មីដល់កសិករ (២០០៥)

២- យ៉ង់ សាំងកុមារ - មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC) (២០០៥) - ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ

3- *JICA 2001 - The Study on Improvement of Marketing System and Post-Harvest Quality Control of Rice in Cambodia.*

៤- អង្គការស៊ីដសេកម្ពុជា(១៩៩៦) - ផលិតកម្មដំណាំស្រូវ

៥- ផលិតកម្មដំណាំស្រូវ *(IRRI)*

៦- សៀវភៅអនុវត្តជាក់ស្តែង អំពីដំណាំស្រូវ *(IRRI)*

៧- នាយកដ្ឋានក្សេត្រសាស្ត្រ + ស៊ីដសេ (១៩៩០) ផលិតកម្មដំណាំស្រូវដែលធានាបានផលច្រើន។

# កំណត់ចំណាំ





សៀវភៅណែនាំនេះជាអំណោយរបស់
ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកជំទាវ
បោះពុម្ពលើកទី ៦ ចំនួន ៥,០០០ ក្បាល